-បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាលស្តីពីនីតិវិធីនៃការបើកផ្តល់មុនដោយអាណត្តិបើកប្រាក់ សំរាប់ចំណាយមូលនិធិសំរាប់ជួសជុលថែទាំផ្លូវថ្នល់

-បានឃើញតំរូវការចាំបាច់ការងារ

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "កសហវ" និង ក្រសួងធនធានទឹក និងឧតុនិយម "ធទឧ" ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-ឯកឧត្តម **វង្សី វិស្សុត** អគ្គលេខាធិការ កសហវ | សហប្រធាន |
| ២-ឯកឧត្តម **ឯម ម៉ុនធឿន** អនុរដ្ឋលេខាធិការ ធទឧ | សហប្រធាន |
| ៣-លោក **ជា ឈុនគៀត** ប្រធាននាយកដ្ឋានផែនការនិងសហប្រតិបត្តិការអន្តរជាតិ ធទឧ | អនុប្រធាន |
| ៤-លោក **ចាន់ សុធី** ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ កសហវ | អនុប្រធាន |
| ៥-លោកបណ្ឌិត **អៀង ស៊ុនលី** ប្រធាននាយកដ្ឋានហិរញ្ញកិច្ច កសហវ | អនុប្រធានប្រចាំការ |
| ៦-លោក **មុយ មុនិន្ទ** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ធទឧ | សមាជិក |
| ៧-លោក **លឹម វីរះ** ប្រធាននាយកដ្ឋានវិស្វកម្ម ធទឧ | សមាជិក |
| ៨-លោក **ស៊ីង សុជល** ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ធទឧ | សមាជិក |
| ៩- លោក **នួច សុខសម្បត្តិ** អនុប្រធានទី១ នាយកដ្ឋានហិរញ្ញកិច្ច កសហវ | សមាជិក |
| ១០-លោក **មាស ចាន់ដេត** អនុប្រធាននាយកដ្ឋានថវិកា កសហវ | សមាជិក |
| ១១-ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងធនធានទឹក និងឧតុនិយម | លេខាធិការ |

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ចសម្របសម្រួលការងារជួសជុល ថែទាំប្រព័ន្ធធារាសាស្ត្រដូចខាងក្រោម :

-កំណត់គោលការណ៍ និង គោលនយោបាយជួសជុល ថែទាំ។

-រៀបចំផែនការជួសជុល ថែទាំ។

-ធ្វើការតំរែតំរង់ទិស និង ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការថែទាំ ។

-រៀបចំគោលនយោបាយ និង ផែនការ សំរាប់តាមដាន និង ត្រួតពិនិត្យការថែទាំ ។

**ប្រការ ៣ :** គណៈកម្មការនេះ ត្រូវជួបប្រជុំរៀងរាល់ពីរខែម្ដង នៅសប្ដាហ៍ទី១ ដើមខែ និង ជួបប្រជុំតាមការចាំបាច់ដែលស្នើឡើងដោយក្រសួងណាមួយក្នុងចំណោមក្រសួងទាំងពីរ ។

**ប្រការ ៤ :** អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងធនធានទឹកឧតុនិយម និង ដូចប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល :**

-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត-ក្រុង

"**ដើម្បីជ្រាប**"

-ដូចប្រការ ១ "**ដើម្បីមុខការ**"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៣៣ សហវ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការកែសំរួលការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ១២០ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការកែសម្រួល ប្រកាស លេខ ២១៨ សហវ ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើត គណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងលើភាពចាំបាច់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# សម្រេច

**ប្រការ១** -

បង្កើត "**ក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស**" ហៅកាត់ "**ករគជ**" ជាសេនាធិការនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងជាចំណុចប្រមូលផ្តុំសម្រាប់ការគ្រប់គ្រងជំនួយបច្ចេកទេសក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ប្រការ២**.-

"**ករគជ**" មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| - អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| - ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | អនុប្រធានប្រចាំការ |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួង ឬតំណាង | សមាជិក |
| - អគ្គាធិការនៃអគ្គាធិការដ្ឋាន | សមាជិក |
| - ប្រធាននាយកដ្ឋានចំណុះក្រសួង | សមាជិក |
| - នាយកវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - ប្រធានអង្គភាពគ្រប់គ្រងសាច់ប្រាក់ | សមាជិក |

**ប្រការ៣**. –

"**ករគជ**" មានភារកិច្ចគ្រប់គ្រង និងសម្របសម្រួលការប្រើប្រាស់ជំនួយបច្ចេកទេស ឲ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដើម្បីគាំទ្រដល់ការរៀបចំ និងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងត្រូវបំពេញតួនាទី ការទទួលខុសត្រូវ ព្រមទាំងសិទ្ធិអំណាច ដូចមានចែងក្នុងលក្ខខណ្ឌយោងនៃក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ៤.** –

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១០

**ចំលងជូនៈ**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាព ចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៤៩......... ប្រក.កសក

[illegible]
ថ្ងៃទី[illegible]...ខែ[illegible]...ឆ្នាំ[illegible]

# ប្រកាស

## ស្តីពី

## ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកែប

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស្រូវស្រាវ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ

- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

# សម្រេច

**ប្រការ ១.-**

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តកែប សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមលក្ខណៈសហគមន៍ព្រៃឈើ ដែលមានទីតាំងស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើកែប នៃខណ្ឌរដ្ឋបាលព្រៃឈើកំពត ។

**ប្រការ ២.-**

ការបង្កើតតំបន់ព្រៃសហគមន៍ក្នុងគោលបំណង :

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្ស និង អភិវឌ្ឍព្រៃសហគមន៍ឱ្យមាននិរន្តភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើ ជាលក្ខណៈប្រពៃណី សម្រាប់ការរស់នៅ ទំនៀមទម្លាប់ និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមសក្តានុពល និង លទ្ធភាពធនធានព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ៣.-**

តំបន់ព្រៃសហគមន៍ក្នុងខេត្តកែបនៃប្រកាសនេះមាន ០១ សហគមន៍ព្រៃឈើ ចែកចេញជា ០១ កន្លែង ដែលមានផ្ទៃដីសរុបចំនួន ៦០ (ហុកសិប)ហិកតា ដូចមានក្នុងផែនទី ទីតាំងព្រៃសហគមន៍ និង ផែនទីសហគមន៍នីមួយៗ ភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ និង ជាប្រព័ន្ធខ្សែព្រំបិទជិត កំណត់ដោយចំណុចគោល និង និយាមកា ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។

**ប្រការ ៤.-**

ដំណើរការរៀបចំ និង ការប្រព្រឹត្តិទៅនៃសហគមន៍ព្រៃឈើ នៅក្នុងតំបន់ព្រៃសហគមន៍ដែលបានកំណត់ក្នុងប្រកាសនេះត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និង ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។

**ប្រការ ៥.-**

ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦.-

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយដ្ឋានផែនការនិងស្ថិតិ ប្រធានមន្ទីរកសិកម្មខេត្តកែប និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី...១០...ខែ.សីហា....ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ចាន់.សារុន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកែប
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ១ : ប្រកាសលេខ ...... ប្រក.កសក ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ......

# ទីតាំងព្រៃសហគមន៍ក្នុងខេត្តកែប



ឧបសម្ព័ន្ធ ២ ៖ ភ្ជាប់ប្រកាសលេខ [illegible] ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ [illegible]

## ទីតាំងព្រៃសហគមន៍ក្នុងខេត្តកែប

| លរ | ឈ្មោះសហគមន៍ | ផ្ទៃដី (ហិកតា) | និយាមកា UTM កំណាត់បណ្តាញប្រឹថពីរិភាគ ឥណ្ឌា ១៩៦០ | | | | | | | ភូមិ | ឃុំ | ស្រុក | ផ្នែករដ្ឋបាលព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ភ្នំពោន | ៦០ | កើត | A | 429683 | 1161668 | B | 429834 | 1160888 | ១ | ពងទឹក | ដំណាក់ចង្អើរ | កែប |
| | | | ត្បូង | B | 429834 | 1160888 | C | 429482 | 1160384 | | | | |
| | | | លិច | C | 429482 | 1160384 | D | 429113 | 1160830 | | | | |
| | | | ជើង | D | 429113 | 1160830 | E | 429086 | 1161928 | | | | |
| | | | | E | 429086 | 1161928 | A | 429683 | 1161668 | | | | |
| សរុប | | ៦០ | | | | | | | | ១ | ១ | ១ | ១ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
លេខ..៤៩......សសរ-អកគជ

# សេចក្តីសម្រេច
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់គំរូឧបសម្ព័ន្ធ ដើម្បីអនុវត្តសារាចរស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានឧក្រាន្តកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើ ច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ

ស/

- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញប្រកាសលេខ ៤២ ដនស បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

## ស ម្រេ ច

**ប្រការ ១:** ដាក់ឱ្យប្រើប្រាស់គំរូឯកសារចំនួន ១៣ ដូចខាងក្រោម ជាឧបសម្ព័ន្ធ នៃសារាចររាជរដ្ឋាភិបាលលេខ ០៣ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន :

១- គំរូតារាងទិន្នន័យទីតាំងសំណង់បណ្តោះអាសន្ន តាមឃុំ សង្កាត់ **(ឧបសម្ព័ន្ធ០១)**

២- គំរូតារាងស្ថិតិរួម នៃទីតាំងសំណង់បណ្តោះអាសន្នក្នុងក្រុង ស្រុក ខណ្ឌ **(ឧបសម្ព័ន្ធ០២)**

៣- គំរូតារាងស្ថិតិរួម នៃទីតាំងសំណង់បណ្តោះអាសន្នក្នុងរាជធានី ខេត្ត **(ឧបសម្ព័ន្ធ០៣)**

៤- គំរូផែនទី ទីតាំងសំណង់បណ្តោះអាសន្នតាមឃុំ សង្កាត់ និងសេចក្តីព្រាងប្លង់ទីតាំងនីមួយៗ **(ឧបសម្ព័ន្ធ០៤)**

៥- គំរូរបាយការណ៍ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងកាធ្វើចំណាត់ថ្នាក់ដីរដ្ឋ លើទីតាំងសំណង់បណ្តោះអាសន្ននៅក្នុងក្រុង ស្រុក ខណ្ឌ **(ឧបសម្ព័ន្ធ០៥)**

៦- គំរូបញ្ជីឈ្មោះគ្រួសារ ដែលបានកាន់កាប់ទីតាំងសំណង់បណ្តោះអាសន្នតាមទីតាំង និងសមាជិកគ្រួសារនីមួយៗតាមទីតាំង **(ឧបសម្ព័ន្ធ០៦)**

៧- គំរូសេចក្តីសង្ខេបមតិសាធារណៈ **(ឧបសម្ព័ន្ធ០៧)**

៨- គំរូរបាយការណ៍នៃការប្រជុំក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ស្តីពីការស្វែងរកដំណោះស្រាយលើទីតាំងសំណង់បណ្តោះអាសន្ន និងបញ្ជីគ្រួសារទទួលយកដំណោះស្រាយ **(ឧបសម្ព័ន្ធ០៨)**

៩- គំរូសេចក្តីជូនដំណឹង ស្តីពីដំណោះស្រាយទីតាំងសំណង់បណ្តោះអាសន្ន និងបញ្ជីភ្ជាប់ **(ឧបសម្ព័ន្ធ០៩)**

១០-គំរូកិច្ចសន្យាផលុបភោគ **(ឧបសម្ព័ន្ធ១០)**

១១-គំរូកិច្ចសន្យាសម្រាប់ផ្តល់សិទ្ធិកម្មសិទ្ធិ **(ឧបសម្ព័ន្ធ១១)**

១២-គំរូកិច្ចសន្យាជួលមានរយៈពេលកំណត់ **(ឧបសម្ព័ន្ធ១២)**

១៣-គំរូបញ្ជីវត្តមានអ្នកចូលរួមកិច្ចប្រជុំនានា **(ឧបសម្ព័ន្ធ១៣)**

**ប្រការ ២:** សេចក្តីសម្រេចនេះ មានប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ភ្នំពេញ ថ្ងៃទី … ខែ … ឆ្នាំ ២០១០

**ទេសរដ្ឋមន្ត្រី**

**អ៊ឹម ឈុនលឹម**

**ឧបសម្ព័ន្ធ ១**
នៃសេចក្ដីសម្រេចលេខ..៤៥....សសរ-អកគជ
ចុះថ្ងៃទី..២៧ ខែ កញ្ញា ២០១០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## គំរូតារាងទិន្នន័យទីតាំងសំណង់បណ្ដោះអាសន្នតាមឃុំ សង្កាត់

**រាជធានី ខេត្ត** ..............................

**ក្រុង ស្រុក ខណ្ឌ** ..............................

**ឃុំ សង្កាត់** ..............................

| ល.រ | **ឈ្មោះទីតាំងសំណង់បណ្ដោះអាសន្ន** (ឬឈ្មោះសហគមន៍ ប្រសិនបើមាន) | **ភូមិ ឬក្រុមទី** | **ចំនួនសំណង់** គ្រប់ប្រភេទ | ទំហំដី ម.ការ៉េ | ចំនួន គ្រួសារ | ប្រជាជន សរុប | **លក្ខណៈរូបវន្តនៃដី** |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| **សរុប** | | | | | | | |

..........ថ្ងៃទី ........ ខែ ........... ឆ្នាំ ២០០......

ឈ្មោះ និងស្នាមមេដៃក្រុមការងារវាល

បានឃើញ និងបានពិនិត្យត្រឹមត្រូវ
ហត្ថលេខា និងត្រា
*(ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់)*

សមាជិក

ឈ្មោះ........................ ឈ្មោះ...................

ប្រធាន

ឈ្មោះ..............

ឈ្មោះ..................... ឈ្មោះ...................... ឈ្មោះ.....................

**ឧបសម្ព័ន្ធ ២.**
នៃសេចក្ដីសម្រេចលេខ ៤៥ សសរ-អកពជ
ចុះថ្ងៃទី ២៧ កញ្ញា ២០១០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# គំរូតារាងស្ថិតិរួមនៃទីតាំងសំណង់បណ្ដោះអាសន្នក្នុងក្រុង ស្រុក ខណ្ឌ

**រាជធានី ខេត្ត ...............................**

**ក្រុង ស្រុក ខណ្ឌ ...........................**

| ១<br>ល.រ | ២<br>ឈ្មោះឃុំ សង្កាត់ | ៣<br>ចំនួនទីតាំង | ៤<br>ចំនួនសំណង់ | ៥<br>ទំហំដី | ៦<br>ចំនួនគ្រួសារ | ៧<br>ចំនួនប្រជាជន | ៨<br>ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| សរុប | | | | | | | |

**<u>សូមជូនភ្ជាប់មកជាមួយនូវ</u> :**

**-តារាងទិន្នន័យនៃទីតាំងសំណង់បណ្ដោះអាសន្ន ក្នុងឃុំ សង្កាត់នីមួយៗចំនួន...................ច្បាប់ ។**

**បានឃើញ និងបានពិនិត្យត្រឹមត្រូវ**

.........ថ្ងៃទី ........ ខែ ........... ឆ្នាំ ២០០......

ហត្ថលេខា និងត្រា

ប្រធានក្រុមការងារដីរដ្ឋក្រុង ស្រុក ខណ្ឌ

*ឈ្មោះ.....................*

**ឧបសម្ព័ន្ធ ៣**
នៃសេចក្ដីសម្រេចលេខ ៤៩ សសរ-អកគជ
ចុះថ្ងៃទី ២៧ កញ្ញា ២០១០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# គំរូតារាងស្ថិតិរួមនៃទីតាំងសំណង់បណ្ដោះអាសន្នក្នុងរាជធានី ខេត្ត

**រាជធានី ខេត្ត ...............................**

| ១<br>ល.រ | ២<br>ឈ្មោះក្រុង ស្រុក ខណ្ឌ | ៣<br>ចំនួនទីតាំង | ៤<br>ចំនួន<br>សំណង់ | ៥<br>ទំហំដី | ៦<br>ចំនួន<br>គ្រួសារ | ៧<br>ចំនួន<br>ប្រជាជន | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| សរុប | | | | | | | |

**<u>សូមជូនភ្ជាប់មកជាមួយនូវ</u> :**

**១-តារាងស្ថិតិរួមនៃទីតាំងសំណង់បណ្ដោះអាសន្នក្នុងក្រុង ស្រុក ខណ្ឌ ចំនួន ..................ច្បាប់**
**២-តារាងទិន្នន័យទីតាំងសំណង់បណ្ដោះអាសន្នក្នុងឃុំ សង្កាត់នីមួយៗចំនួន.................ច្បាប់ ។**

**បានឃើញ និងបានពិនិត្យត្រឹមត្រូវ**

.........ថ្ងៃទី ....... ខែ .......... ឆ្នាំ ២០០......

ហត្ថលេខា និងត្រា
ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ
រាជធានី ខេត្ត.....................

*ឈ្មោះ.......................*

**ឧបសម្ព័ន្ធ ៤**

នៃសេចក្ដីសម្រេចលេខ ៤៥ សសរ-អកកជ
ចុះថ្ងៃទី ២៧ កញ្ញា ២០១០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ........................
ក្រុង ស្រុក ខណ្ឌ ........................
ឃុំ សង្កាត់ ........................

## គំរូផែនទីទីតាំងសំណង់បណ្ដោះអាសន្នតាមឃុំ សង្កាត់

***សម្គាល់ :*** ប្រើប្រាស់**ផែនទីឃុំ សង្កាត់**ដែលបានទទួលពីក្រសួងមហាផ្ទៃ ឬក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ចំណុចដៅទីតាំងសំណង់បណ្ដោះអាសន្នទីមួយៗត្រូវបង់លេខសម្គាល់ សម្រាប់យោងទៅលើប្លង់បង្ហាញទីតាំងនីមួយៗ ដែលមានឈ្មោះទីតាំង និងមានពណ៌បញ្ជាក់លក្ខណៈរូបវន្តនៃដី ។

**ឧបសម្ព័ន្ធ ៩**
នៃសេចក្តីសម្រេចលេខ ៤៩ សសរ-អកគជ
ចុះថ្ងៃទី ២៧ កញ្ញា ២០១០

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## គំរូរបាយការណ៍
## ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ
## លើទីតាំងសំណង់បណ្តោះអាសន្ន នៅក្នុងក្រុង ស្រុក ខណ្ឌ....................

យោងសេចក្តីសំរេចលេខ......................ចុះថ្ងៃទី ..........................របស់ឯកឧត្តមប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ .......... បានចាត់តាំងក្រុមការងារវាលចំនួន.... ក្រុម ដើម្បីដំណើការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងកំណត់លក្ខណៈរូបវន្តនៃដីរដ្ឋ ក្នុងចំណុចទីតាំងដែលមានសំណង់បណ្តោះអាសន្នតាំងនៅ ក្នុងឃុំ សង្កាត់ចំនួន.......ក្នុងចំណោមឃុំ សង្កាត់ទាំង.....ក្នុងក្រុង ស្រុក ខណ្ឌទាំងមូល ចាប់ពីថ្ងៃទី.....ខែ...........ឆ្នាំ........ដល់ថ្ងៃទី ....ខែ.........ឆ្នាំ...... ..។

*សូមជូនភ្ជាប់នូវបញ្ជីវត្តមាននៃសមាជិកចូលរួមប្រជុំ ។*

បន្ទាប់ពីបានទទួលរបាយការណ៍ តារាងទិន្នន័យ និងផែនទីនៃទីតាំងសំណង់បណ្តោះអាសន្នតាមឃុំ សង្កាត់ទាំង.... ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយមានសមាជិកចំពោះកិច្ចចំនួន......រូបចូលរួមផង បានជួបប្រជុំគ្នា ដើម្បីពិនិត្យនិងពិភាក្សាស្វែងរកការឯកភាពគ្នា លើចំណុចទីតាំងសំណង់បណ្តោះអាសន្នទាំង........ និងលក្ខណៈរូបវន្តនៃដីតាមទីតាំងនីមួយៗ ក្នុងឃុំ សង្កាត់ទាំងនោះ។

សមាជិកក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងសមាជិកចំពោះកិច្ច អវត្តមាន មាន :

- -លោកស្រី.......................... ប្រធានការិយាល័យ......................
- -លោក .............................. ប្រធានការិយាល័យ.......................ជាប់បេសកកម្ម
- -លោក.............................. តំណាងសហគមន៍............
- -លោកស្រី.......................... តំណាងអង្គការមិនមែនរដ្ឋាភិបាល.....................
- -លោកស្រី......................... តំណាងក្រុមសំណង់បណ្តោះអាសន្នភូមិ ៥

**<u>ដំណើរការ និងលទ្ធផលនៃការប្រជុំ</u> :**

១-ក្នុងដំណើរការនៃការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការកំណត់លក្ខណៈរូបវន្តនៃដីរដ្ឋក្នុងចំណុចដែលមានទីតាំងសំណង់បណ្តោះអាសន្ននីមួយៗក្នុងឃុំ សង្កាត់ទាំងអស់ តំណាងអង្គភាពរដ្ឋ អាជ្ញាធរដែនដី អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ក្នុងក្រុង ស្រុក ខណ្ឌ បានសហការគ្នាល្អជាមួយក្រុមការងារវាល និងក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ លើកលែងតែនៅ.....................( *ប្រសិនបើមានហេតុការណ៍មិនប្រក្រតីណាមួយកើតឡើងនៅទីតាំងណាមួយ និងសូមបរិយាយបញ្ជាក់ករណីនោះ*) ។

២-ក្រុមការងារវាលបានចុះពិនិត្យទីតាំងសំណង់បណ្តោះអាសន្នមួយម្តងៗ ស្រង់ព័ត៌មានពាក់ព័ន្ធនឹង ៖

- ចំនួនសំណង់គ្រប់ប្រភេទ ដែលក្នុងនោះមានកត់ត្រាចំនួនសំណង់រឹងមាំ
- ចំនួនគ្រួសារ និងចំនួនប្រជាជនដែលរស់នៅក្នុងទីតាំងនោះ *(ពិភាក្សាជាមួយប្រធានភូមិ)*
- ភស្តុតាងនៃការកាន់កាប់ដីរបស់អ្នកស្នាក់នៅ *(អាចថតដោយម៉ាស៊ីនថត ឬថតចម្លង)*
- គូសដៅទីតាំងនីមួយៗនៅលើផែនទីឃុំ ដោយបង់លេខសម្គាល់ឈ្មោះទីតាំងនីមួយៗ
- គូសព្រាងប្លង់ទីតាំងនីមួយៗ និងការប៉ាន់ប្រមាណទំហំផ្ទៃក្រឡានៃដីទីតាំងនីមួយៗ និង
- បញ្ជាក់នូវលក្ខណៈរូបវន្តនៃដីតាមទីតាំងទាំងនោះ ។

ក្នុងការប្រជុំ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយមានសមាជិកចំពោះកិច្ចចូលរួមផង បានស្តាប់របាយការណ៍របស់ក្រុមការងារវាល ដែលគូសបង្ហាញនូវការប្រកាសអះអាងដីរដ្ឋ ព្រមទាំងការផ្តល់ព័ត៌មានផ្សេងៗ ដែលបានសង្កេតឃើញជាក់ស្តែងតាមទីតាំងនីមួយៗ *(មានផែនទីរូបថតពីអាកាសឆ្នាំ ២០០២ រូបថត/ថតចម្លងលិខិតកាន់កាប់ដីធ្លីរបស់អ្នកស្នាក់នៅតាមទីតាំងនីមួយៗ...ការរស់នៅ...)* សម្រាប់ការពិចារណារបស់អង្គប្រជុំ។ បន្ទាប់ពីការពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នាលើទីតាំងមួយម្តងៗ ដោយផ្អែកលើ..... *( មាត្រា ៤ នៃអនុក្រឹត្យលេខ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ ៤២ ដនស.បក ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ឬតាមលក្ខណៈរូបវន្តនៃដី)*... អង្គប្រជុំបានសម្រេចឯកភាពគ្នាថា ទីតាំងទាំង...........កន្លែងស្ថិតនៅលើដីរដ្ឋ (និងមានចំនួន.........កន្លែងជាដីឯកជនដែលមានឯកសារគ្រប់គ្រាន់) ។ សម្រាប់ទីតាំងដែលមានការឯកភាពគ្នាហើយ អង្គប្រជុំបានស្នើសុំឱ្យសមាជិកទាំងអស់របស់ខ្លួន ចុះហត្ថលេខាលើពង្រាងប្លង់ទីតាំងនោះ ដែលមានបញ្ជាក់ឈ្មោះ ទីតាំង និងភូមិ ឃុំ សង្កាត់ ។

ចំពោះទីតាំង........................ . ត្រូវធ្វើការស្រាវជ្រាវបន្ថែម................. បន្តការពិចារណា ....... និងធ្វើការពិភាក្សាជាមួយ............ .................................បន្តទៀត ។

៣-បន្ទាប់មក ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ បានបន្តប្រជុំដើម្បីកំណត់អាណត្តិកាន់កាប់ដី និងចំណាត់ថ្នាក់ដីរដ្ឋនៃទីតាំងនីមួយៗ ដោយបញ្ជាក់ឈ្មោះស្ថាប័នដែលត្រូវកាន់កាប់ដីនៃទីតាំងនោះ និងចំណាត់ថ្នាក់ដីជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ។ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌបានពិភាក្សាគ្នាយ៉ាងផុសផុល ដោយយកសេចក្តីសម្រេចលេខ ៥២ សសរ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០០៦ ទាក់ទងនឹងឯកសារលក្ខណៈវិនិច្ឆ័យក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋជាមូលដ្ឋាន។ ក្នុងការពិភាក្សា អង្គប្រជុំបានឯកភាពគ្នាក្នុងការរៀបចំធ្វើតារាងសង្ខេបនូវលទ្ធផលជា ២ តារាងគឺ ៖ (ក) តារាងបញ្ជាក់ការ**ឯកភាពគ្នា**លើអាណត្តិកាន់កាប់ដីរដ្ឋ និងចំណាត់ថ្នាក់ដីរដ្ឋ និង **(ខ)**តារាងបង្ហាញមតិ**មិនឯកភាពគ្នា**លើអាណត្តិកាន់កាប់ដីរដ្ឋ និងចំណាត់ថ្នាក់ដីរដ្ឋ (ដែលក្នុងករណីមានសមាជិកណាម្នាក់មិនយល់ស្របលើចំណុចណាមួយនៃទីតាំងទាំងនោះ គេអាចសរសេរបញ្ជាក់មតិយោបល់របស់គេខ្ទាស់ភ្ជាប់នឹងសេចក្តីព្រាងប្លង់ទីតាំងនោះ) ។

៤-ក្រោយពីការប្រជុំ និងសម្រេចបានជាតារាងដែលបញ្ជាក់ពីអាណត្តិកាន់កាប់ដីរដ្ឋ និងចំណាត់ថ្នាក់ដីរដ្ឋ និងការគូសដៅបង្ហាញទីតាំងសំណង់បណ្តោះអាសន្នទាំងអស់លើផែនទីឃុំ សង្កាត់ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ បានធ្វើការបិទផ្សាយជាសាធារណៈ នៅតាមតាមសាលាឃុំ សង្កាត់ និងទីតាំងសំណង់បណ្តោះអាសន្នទាំងនោះរយៈពេល ៣០ ថ្ងៃ និងមានចាត់តាំងមន្ត្រីឱ្យរង់ចាំទទួលមតិសាធារណៈ តាមសាលាឃុំ សង្កាត់ទៀតផង ។

ក្នុងការបិទផ្សាយនេះ ក្រុមការងារដីរដ្ឋបានទទួលមតិសាធារណៈ សំណើ និងសំណូមពរផ្សេងៗចំនួន .........ច្បាប់ និងបានរៀបចំធ្វើសេចក្តីសង្ខេបមតិយោបល់ទាំងនោះ ដើម្បីបិទផ្សាយជាសាធារណៈរយៈពេល ៣ ថ្ងៃថែមទៀត ។

លទ្ធផលនៃការប្រជុំសម្របសម្រួលរបស់ក្រុមការងារដីរដ្ឋ មានដូចតទៅ :

**ក) តារាងបញ្ជាក់ការឯកភាពគ្នាលើអាណត្តិកាន់កាប់ដីរដ្ឋ និងចំណាត់ថ្នាក់ដីរដ្ឋ**

| ល.រ | ឈ្មោះឃុំ សង្កាត់ និងភូមិ | លេខ និងឈ្មោះទីតាំងសំណង់ បណ្តោះអាសន្ន ឬសហគមន៍ | ទំហំដី ជាម៉ែត្រការ៉េ | ឯកភាពគ្នាចំពោះ | |
|---|---|---|---|---|---|
| | | | | ស្ថាប័នកាន់កាប់ | ចំណាត់ថ្នាក់ជាដី |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

**ខ) តារាងបង្ហាញមតិមិនឯកភាពគ្នាលើអាណត្តិកាន់កាប់ដីរដ្ឋ និងចំណាត់ថ្នាក់ដីរដ្ឋ**

| ល.រ | ឈ្មោះឃុំ សង្កាត់ | ឈ្មោះភូមិ និងទីតាំងសំណង់ បណ្តោះអាសន្ន ឬសហគមន៍ | ទំហំដី គិតជាម៉ែត្រការ៉េ | **សម្លេងនៃមតិមិនឯកភាព** | |
|---|---|---|---|---|---|
| | | | | ស្ថាប័នទី១ ស្ថាប័នទី២ | សាធារណៈ ឯកជន |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

៥-របាយការណ៍ដែលមានភ្ជាប់មតិសាធារណៈ យោបល់របស់សមាជិកចំពោះកិច្ចលើការកំណត់ទីតាំងសំណង់បណ្តោះអាសន្ន និងលក្ខណៈរូបវន្តនៃដី ព្រមទាំងមតិនានានៃសមាជិកក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធនឹងអាណត្តិកាន់កាប់ដីរដ្ឋ និងចំណាត់ថ្នាក់ដីរដ្ឋ និងត្រូវបានថតចម្លងជូនដល់គ្រប់សមាជិកក្រុមការងារដីរដ្ឋថ្នាក់ ក្រុង ស្រុក ខណ្ឌ ដើម្បីផ្តល់យោបល់បន្ថែមរយៈពេល ៣ ថ្ងៃ មុននឹងគោរពជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ពិនិត្យនិងសម្រេច ។

៦-<u>សេចក្តីសន្និដ្ឋាន</u> : ជាទូទៅ ការប្រជុំមានដំណើរការល្អ.......... *(ឬតឹងតែង ដោយមកពី...........)* ។ តាមយោបល់ភាគច្រើនយល់ថា :

ក-ទីតាំងដីរដ្ឋលេខ................ក្នុងភូមិ........... ឃុំ...... គួរចាត់ថ្នាក់ជា (ដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ) ពីព្រោះចាប់តាំងពី.........មានការចូលកាន់កាប់...........និងត្រូវធ្វើការចុះបញ្ជីដីនោះទៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

ខ-គួររៀបចំដោះស្រាយទីតាំងលេខ...............សម្រាប់...................................................................................................................................................... ។ល។ និង ។ល។

គ-ដីឡូតិ៍លេខ.................ត្រូវបានពិនិត្យឃើញមានឯកសារគ្រប់គ្រាន់ ដែលគួរដោះស្រាយតាមច្បាប់ភូមិបាល ។

**សូមជូនភ្ជាប់មកជាមួយនូវ :**

-លិខិតចាត់តាំងក្រុមការងារវាលទាំង .........ក្រុម ចំនួន............... ច្បាប់

-បញ្ជីវត្តមានឈ្មោះសមាជិកចំពោះកិច្ចតាមក្រុមការងារវាលចំនួន............ ច្បាប់

-ផែនទីដែលមានដៅចំណុចទីតាំងសំណង់បណ្តោះអាសន្ន តាមឃុំ សង្កាត់នីមួយៗចំនួន.............. ច្បាប់

-ពង្រាងប្លង់ទីតាំងសំណង់បណ្តោះអាសន្ន ចំនួន .................................... ច្បាប់

-ឯកសារបង្ហាញការមិនឯកភាពលើការកំណត់ថាជាទីតាំងសំណង់បណ្តោះអាសន្នចំនួន.............. ច្បាប់

-លិខិតបង្ហាញមតិមិនឯកភាពលើការកំណត់អាណត្តិកាន់កាប់ជីវរដ្ឋ ចំនួន............... ច្បាប់

-លិខិតបង្ហាញការមតិមិនឯកភាពលើចំណាត់ថ្នាក់ជីវរដ្ឋ ចំនួន................................ ច្បាប់

-សេចក្តីសង្ខេបមតិសាធារណៈ និងសំណូមពរផ្សេងៗ ចំនួន.............. ........................... ច្បាប់ ។

សូមឯកឧត្តមប្រធានគណៈកម្មាធិការទទួលនូវការគោរពអំពីខ្ញុំ ។

.............ថ្ងៃទី ............ ខែ ................ ឆ្នាំ ២០០..........

ប្រធានក្រុមការងារជីវរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ

ហត្ថលេខា និង ត្រា

**ឧបសម្ព័ន្ធ ៦**

នៃសេចក្តីសម្រេចលេខ.៤៩.....សសរ-អកគជ
ចុះថ្ងៃទី..២៧...កញ្ញា.២០១០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គំរូបញ្ជីឈ្មោះគ្រួសារដែលបានកាន់កាប់ទីតាំង**
**សំណង់បណ្តោះអាសន្នលេខ........................**
**ក្នុងភូមិ...............ឃុំ សង្កាត់..................**
**ក្រុង ស្រុក ខណ្ឌ ................................**
**រាជធានី ខេត្ត ..................................**

<u>បញ្ជីនេះត្រូវបិទផ្សាយជាសាធារណៈរយៈពេល ៣០ ថ្ងៃ នៅទីតាំងសំណង់បណ្តោះអាសន្ន និងនៅសាលាឃុំ សង្កាត់ ។</u>

| ល.រ | ឈ្មោះមេគ្រួសារ | ភេទ | អាយុ | ចំនួនសមាជិកគ្រួសារទាំងអស់ | ស្រុកកំណើត | ថ្ងៃខែឆ្នាំចូលកាន់កាប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| សរុប | | | | | | | |

***សម្គាល់ :*** អ្នកធ្វើបញ្ជីត្រូវស្រង់តែឈ្មោះគ្រួសារដែលបានចូលកាន់កាប់ដីនិងជាម្ចាស់សំណង់ ដោយមិនរាប់បញ្ចូលអ្នកជួលស្នាក់នៅឡើយ ។

- *ម្ចាស់សំណង់ជាអ្នកស្នាក់នៅក្នុងទីតាំងនេះ អាចធ្វើការតវ៉ា ប្រសិនបើពិនិត្យឃើញថា គ្មានឈ្មោះរបស់ខ្លួន ឬមានភាពមិនត្រឹមត្រូវណាមួយ ។*
- *ការកែប្រែខុសពីស្ថិតិក្នុងបន្ទុកគ្រួសារ មិនអាចធ្វើបានដោយគ្មានយោបល់ឯកភាពពីក្រុមការងារវាល និងសាមីគ្រួសារឡើយ ។*

**ធ្វើនៅ................ ថ្ងៃទី .... ខែ......... ឆ្នាំ ........**

**ហត្ថលេខា និងឈ្មោះ មន្ត្រីទទួលខុសត្រូវធ្វើបញ្ជី**

**ថ្ងៃទី ....... ខែ.......... ឆ្នាំ ............**

**ហត្ថលេខា និងត្រាមេឃុំ ចៅសង្កាត់**

**ឧបសម្ព័ន្ធ ៦-១**
នៃសេចក្ដីសម្រេចលេខ...៤៩...សសរ-អកគជ
ចុះថ្ងៃទី...២៧...កញ្ញា ២០១០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ស្ថិតិសមាជិកគ្រួសារនីមួយៗ

**ក្នុងទីតាំងសំណង់បណ្ដោះអាសន្នលេខ...............**
**ស្ថិតក្នុងភូមិ ឬក្រុម..............ឃុំ សង្កាត់.................**
**ក្រុង ស្រុក ខណ្ឌ ..............................**
**រាជធានី ខេត្ត ..............................**

| ល.រ | ឈ្មោះមេគ្រួសារ | អាយុ | ភេទ | ត្រូវជាអ្វីនឹងមេគ្រួសារ | ស្រុកកំណើត | មុខរបរ | ថ្ងៃខែឆ្នាំចូលស្នាក់នៅ | ជាអ្នកជួល ឬម្ចាស់សំណង់ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុប | | | | | | | | |

ធ្វើនៅ................ ថ្ងៃទី .... ខែ......... ឆ្នាំ ...........
ឈ្មោះ និងស្នាមមេដៃមេគ្រួសារនិងសហព័ទ្ធ

ឈ្មោះ និងស្នាមមេដៃសមាជិកក្រុមការងារវាលចុះអង្កេត

**ឧបសម្ព័ន្ធ ៧**

នៃសេចក្តីសម្រេចលេខ ៤៩.....សសរ-អកពជ
ចុះថ្ងៃទី ២៧ កញ្ញា ២០១០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## គំរូសេចក្តីសង្ខេបមតិសាធារណៈ

ក្រុង ស្រុក ខណ្ឌ ..............
ក្រុមការងារដីរដ្ឋថ្នាក់ក្រុង សុក ខណ្ឌ

ក្នុងរយៈពេលបិទផ្សាយជាសាធារណៈចំនួន ៣០ (សាមសិប) ថ្ងៃ ពីថ្ងៃទី ខែ ឆ្នាំ ដល់ថ្ងៃទី ខែ ឆ្នាំ នូវលទ្ធផលនៃការប្រជុំក្រុមការងារដីរដ្ឋថ្នាក់ក្រុង សុក ខណ្ឌ ស្តីពីដំណើរការនៃការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ព្រមទាំងការស្រង់ព័ត៌មានពាក់ព័ន្ធនឹងគ្រួសារអ្នកស្នាក់នៅក្នុងទីតាំងសំណង់បណ្តោះអាសន្នទាំង......កន្លែងក្នុងក្រុង/ស្រុក/ខណ្ឌទាំងមូល ក្រុមការងារដីរដ្ឋ ថ្នាក់ក្រុង ស្រុក ខណ្ឌ បានទទួលមតិសាធារណៈចំនួន ........ ច្បាប់ និងសូមធ្វើសេចក្តីសង្ខេបដូចតទៅ :

☐ **អំពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ** ..........................................................
....................................................................................................................................................
....................................................................................................................................................

☐ **ការស្រង់ស្ថិតិគ្រួសារក្នុងបន្ទុក** ....................................................................................................
....................................................................................................................................................
....................................................................................................................................................

☐ **មតិផ្សេងៗ** ..........................................
..............................................................

☐ **សំណើ និងសំណូមពររបស់ក្រុមការងារដីរដ្ឋលើទីតាំង**..............................................
....................................................................................................................................................

***ថ្ងៃទី ...... ខែ ......... ឆ្នាំ ២០0........***

***ហត្ថលេខា និង ឈ្មោះមន្ត្រីសង្ខេបមតិ***

***............ថ្ងៃទី ...... ខែ ..........ឆ្នាំ ២០0......***

***ប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ***

***ហត្ថលេខា និង ត្រា***

**ឧបសម្ព័ន្ធ ៨**
នៃសេចក្តីសម្រេចលេខ...៤៩...សសរ-អកគដ
ចុះថ្ងៃទី...២៧...កញ្ញា ២០១០...

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត ........................
ក្រុង ស្រុក ខណ្ឌ ........................

*ថ្ងៃទី .....ខែ ............ ឆ្នាំ .........*

## គំរូរបាយការណ៍នៃការប្រជុំក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ស្តីពីការស្វែងរកដំណោះស្រាយលើទីតាំងសំណង់បណ្តោះអាសន្ន................ ក្នុងឃុំ សង្កាត់..................ក្រុង ស្រុក ខណ្ឌ..........................

**សូមគោរពជូន**
**ឯកឧត្តម ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋរាជធានី ខេត្ត...........**

-ផ្អែកលើការវិវឌ្ឍរីកចម្រើននៃមូលដ្ឋាន និងជាពិសេសការចាំបាច់ ( *ក្នុងការពង្រីកផ្លូវដើម្បីដោះស្រាយចរាចរណ៍ ឬ សម្រាប់បម្រើផលប្រយោជន៍សាធារណ)*....... និង..........

-យោងសេចក្តីសម្រេចរបស់...................*(ប្រសិនបើមាន)*

ខ្ញុំសូមជម្រាបជូនឯកឧត្តមប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តថា កាលពីថ្ងៃទី... .ខែ........ ឆ្នាំ........ក្រុមការងារដីរដ្ឋថ្នាក់ក្រុង/ស្រុក/ខណ្ឌបានអញ្ជើញសមាជិកចំពោះកិច្ច និងតំណាងប្រជាពលរដ្ឋ*(ឬប្រជាពលរដ្ឋទាំង......គ្រួសារ(ប្រសិនបើអាចធ្វើបាន)*នៃសហគមន៍ ...............ស្ថិតក្នុងភូមិ ឬក្រុម...............ឃុំ សង្កាត់ .......... ក្រុង ស្រុក ខណ្ឌ .............. មករួមប្រជុំពិភាក្សាស្វែងរកដំណោះស្រាយរួមគ្នា លើបញ្ហាផ្លាស់ប្តូរទីតាំងខាងលើ ដើម្បីឆ្លើយតបទៅនឹង ...........................*(ការចាំបាច់នៃផលប្រយោជន៍សាធារណៈ)* ។ ការពិភាក្សាបានប្រព្រឹត្តទៅអស់រយៈពេល.........ម៉ោងនិង........នាទី និងបានឈានដល់ការសម្រេចដូចតទៅ :

**១. មតិយោបល់លើដំណោះស្រាយទីតាំង............... នៅភូមិ ឬក្រុម...................ក្នុងឃុំ សង្កាត់............:**

ជាទូទៅ តំណាងប្រជាពលរដ្ឋបានយល់ពីភាពចាំបាច់របស់មូលដ្ឋាន និងព្រមទទួលយកសំណើរបស់អាជ្ញាធរក្នុងការប្តូរទីតាំងរបស់ពួកគាត់ ដោយ.........................................................................................................................
.................................................................................................................................................................
.................................................................................................................................................................

តាមការស្ទាបស្ទង់
.................................................................................................................................................................
.................................................................................................................................................................
.................................................................................................................................................................

.................................................................................................................................................................................

.................................................................................................................................................................

**២. យោបល់របស់ក្រុមការងារ.......................................................................................**

..............................................................

*សូមជូនភ្ជាប់មកជាមួយនូវ :*

- បញ្ជីវត្តមានអ្នកចូលរួមប្រជុំ
- បញ្ជីឈ្មោះគ្រួសារដែលយល់ព្រមទទួលយកដំណោះស្រាយ *(តាមការព្រាងទុកដោយក្រុមប្រឹក្សាឃុំ សង្កាត់)*
- ឯកសារឯណាផ្សេងៗ ដែលភាគីពាក់ព័ន្ធបានព្រមព្រៀង *( ដូចជា : ប្លង់លម្អិតអំពីទីតាំងថ្មីដែលត្រូវប្តូរទៅនៅ ឬ ប្លង់លម្អិតនៃការអភិវឌ្ឍនៅនឹងកន្លែង ក្នុងករណីដែលមានទីតាំងអនុគ្រោះ.... )*

***ថ្ងៃទី ....... ខែ............ ឆ្នាំ...........***
***ប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ***

*ហត្ថលេខា និងត្រា*

ថ្ងៃទី ............ ខែ............ ឆ្នាំ ................
យោបល់របស់ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត

...............................................................

ហត្ថលេខា និងត្រា

**ឧបសម្ព័ន្ធ ៨-១**
នៃសេចក្ដីសម្រេចលេខ..៤៩.....សសរ-អកគជ
ចុះថ្ងៃទី...២៧...កញ្ញា..២០១០..

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត ..........................
ក្រុង ស្រុក ខណ្ឌ ..........................
ឃុំ សង្កាត់............................

## បញ្ជីឈ្មោះគ្រួសារទទួលយកដំណោះស្រាយ
## ក្នុងទីតាំងសំណង់បណ្ដោះអាសន្នលេខ.......... ភូមិ ឬក្រុម......................

| ល.រ | ឈ្មោះមេគ្រួសារដែលព្រមទទួលយកដំណោះស្រាយ | ចំនួនសមាជិកក្នុងបន្ទុកគ្រួសារ | មុខរបរ | ស្រុកកំណើត | ដំណោះស្រាយដែលបានឯកភាពទទួល | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| សរុប | | | | | | |

**ជ. ក្រុមប្រឹក្សាឃុំ សង្កាត់**
**មេឃុំ ចៅសង្កាត់**

ហត្ថលេខា និងត្រា

*ថ្ងៃទី ............. ខែ.............. ឆ្នាំ .................*
*បានឃើញ និងឯកភាព*
*ប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ*
*ហត្ថលេខា និងត្រា*

**ថ្ងៃទី ............. ខែ.............. ឆ្នាំ ...............**
**បានឃើញ និងឯកភាព**
